**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:..៩២..សសរ..**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មការរៀបចំគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ

---

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /១២០៧ /០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៣០៣ /១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ

- យោងស្មារតីអង្គប្រជុំថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩របស់គណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ

**សម្រេច**

**ប្រការ១:** បង្កើតលេខាធិការដ្ឋាននៃគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម បណ្ឌិត **ជេត ជាលី** | សមាជិក គ.ស.ម.ក.និង ក.ស.វ. | **ប្រធាន** |
| ២-លោក **ម៉ែន ស៊ីផុល** | ប្រធាននាយកដ្ឋានស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំ នៃអគ្គលេខាធិការដ្ឋាន គ.ទ.ក. | **សមាជិក** |
| ៣-លោក **ម៉ិត សុម៉េត** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអគ្គលេខាធិការដ្ឋាន គ.ទ.ក. | **សមាជិក** |

**ប្រការ២:** លេខាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា
- រៀបចំ និងសម្របសម្រួលរាល់ការងារ និងកិច្ចប្រជុំរបស់គណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ
- ទទួលភារកិច្ចមួយចំនួនទៀតតាមការប្រគល់ជូនពីប្រធានគណកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ

**ប្រការ៣:** ប្រធាន គណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ០៦ ឆ្នាំ២០០៩

សុខ .អាន

**កន្លែងទទួល:**

-ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
-គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន គ.ទ.ក.
-រាជកិច្ច ✓
-ដូចប្រការ៣
-ឯកសារ-កាលប្បវត្តិ